# នីតិវិធីបណ្តឹងសាទុក្ខសម្រាប់ដំណោះស្រាយចំពោះជនពិការ

ប្រសិនបើអ្នកបានស្នើសុំដំណោះស្រាយពីប្រព័ន្ធតុលាការសម្រាប់ជនពិការ ហើយបើអ្នកគិតថាសេចក្តីសម្រេចនោះពុំបានអនុវត្តតាមអង្គនីតិតុលាការរដ្ឋ Maine គោលនយោបាយស្តីពីការទទួលបានសម្រាប់ជនពិការ អ្នកអាចឲ្យអ្នកណាម្នាក់ផ្សេងទៀតត្រួតពិនិត្យលើសេចក្តីសម្រេចនោះបាន។

សំណើសុំរបស់អ្នកសម្រាប់ការត្រួតពិនិត្យនេះហៅថាបណ្តឹងសាទុក្ខ។ អ្វីដែលអ្នកត្រូវធ្វើគឺអាស្រ័យលើថាតើសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងដោយៈ

(1) **មន្ត្រីយុត្តិធម៌** (តុលាការ ចៅក្រម ចៅក្រមថ្នាក់ក្រោម) ឬ
(2) បុគ្គលិកអង្គនីតិតុលាការដែល**មិនមែនជាមន្ត្រីយុត្តិធម៌**។

## <u>សេចក្តីសម្រេចធ្វើឡើងដោយមន្ត្រីយុត្តិធម៌</u>

ដើម្បីស្វែងរកការត្រួតពិនិត្យលើសេចក្តីសម្រេចទៅលើដំណោះស្រាយដោយ**មន្ត្រីយុត្តិធម៌** អ្នកត្រូវដាក់បណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនោះស្របទៅតាមវិធានរដ្ឋប្បវេណី ឬនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋ Maine។ អ្នកត្រូវរួមបញ្ចូលនូវច្បាប់ចតចម្លងនៃសេចក្តីសម្រេច សាលក្រម ឬដីកាជាក់ស្តែងណាមួយដែលអ្នកចង់ឲ្យគេត្រួតពិនិត្យ។ ប្រសិនបើអ្នកមានមេធាវីម្នាក់ មេធាវីនោះអាចជួយអ្នកស្នើសុំការត្រួតពិនិត្យនេះបាន។

## <u>សេចក្តីសម្រេចធ្វើឡើងដោយបុគ្គលិកអង្គនីតិតុលាការ ដែលមិនមែនជាមន្ត្រីយុត្តិធម៌</u>

ដើម្បីស្វែងរកការត្រួតពិនិត្យលើសេចក្តីសម្រេចចំពោះដំណោះស្រាយដែលធ្វើឡើងដោយបុគ្គលិកតុលាការដែល**មិនមែនជាមន្ត្រីយុត្តិធម៌** អ្នកត្រូវដាក់បណ្តឹងសាទុក្ខរបស់អ្នកជាលាយលក្ខណ៍អក្សរ។

សូមប្រើទម្រង់បែបបទបណ្តឹងសាទុក្ខសម្រាប់ដំណោះស្រាយចំពោះជនពិការ។ អ្នកអាចទទួលបានច្បាប់ចតចម្លងនៃទម្រង់បែបបទបណ្តឹងសាទុក្ខនៅគេហទំព័រអង្គនីតិតុលាការតាមរយៈ៖ www.courts.maine.gov/citizen_help/access_interp.html។

នៅក្នុងបណ្តឹងសាទុក្ខរបស់អ្នក អ្នកត្រូវពន្យល់ជាលាយលក្ខណ៍អក្សរនៅលើទម្រង់បែបបទបណ្តឹងសាទុក្ខនោះអំពី៖

(1) សេចក្តីសម្រេចដែលបានធ្វើឡើង
(2) កាលបរិច្ឆេទនៃការធ្វើសេចក្តីសម្រេច
(3) បុគ្គលដែលធ្វើសេចក្តីសម្រេច
(4) មូលហេតុដែលអ្នកគិតថាសេចក្តីសម្រេចនោះពុំត្រឹមត្រូវ។

អ្នកត្រូវផ្ញើបណ្តឹងសាទុក្ខរបស់អ្នកទៅកាន់អ្នកសម្របសម្រួលសេវាតុលាការនៅការិយាល័យរដ្ឋបាលតុលាការ តាមប្រអប់ សំបុត្រ 4820, Portland, ME 04112–4820 ឬអ្នកអាចផ្ញើអ៊ីម៉ែលទៅកាន់៖ accessibility@courts.maine.gov

ប្រសិនបើអ្នកពុំអាចអនុវត្តតាមនីតិវិធីបណ្តឹងសាទុក្ខបានដោយសារបញ្ហាពិការភាព សូមទំនាក់ទំនងទៅកាន់អ្នកសម្របសម្រួលសេវាតុលាការតាមរយៈលេខ 207-822-0718។

**ចំណុចសំខាន់៖ អង្គនីតិតុលាការ ត្រូវទទួលបណ្តឹងសាទុក្ខក្នុងរយៈពេល 21 ថ្ងៃប្រតិទិនបន្ទាប់ពីថ្ងៃនៃសេចក្តីសម្រេចនោះ!**
អ្នកសម្របសម្រួលសេវាតុលាការ នឹងធ្វើការត្រួតពិនិត្យបណ្តឹងសាទុក្ខរបស់អ្នក និងចេញសេចក្តីសម្រេចមួយក្នុងរយៈពេល 48 ថ្ងៃបន្ទាប់ពីអ្នកបានដាក់ពាក្យបណ្តឹងសាទុក្ខ លើកលែងតែការត្រួតពិនិត្យនេះមិនអាចធ្វើចប់សព្វគ្រប់បានក្នុងពេលនោះ។

ប្រសិនបើអ្នកសម្របសម្រួលសេវាតុលាការបានធ្វើសេចក្តីសម្រេចដែលអ្នកបានប្តឹងសាទុក្ខនោះរដ្ឋបាលតុលាការរបស់រដ្ឋ នឹងធ្វើការត្រួតពិនិត្យ និងចេញសេចក្តីសម្រេចក្នុងរយៈពេល 48 ម៉ោងបន្ទាប់ពីអ្នកបានដាក់ពាក្យបណ្តឹងសាទុក្ខ លើកលែងតែការត្រួតពិនិត្យមិនអាចធ្វើចប់សព្វគ្រប់បានក្នុងរយៈពេលនោះ។

បន្ទាប់ពីការត្រួតពិនិត្យ ប្រសិនបើគេបានសម្រេចថា អ្នកមានសិទ្ធិក្នុងការទទួលបានដំណោះស្រាយចំពោះជនពិការ នោះអ្នកសម្របសម្រួលសេវាតុលាការនឹងផ្តល់ជូននូវដំណោះស្រាយនោះដល់អ្នក។

## ព័ត៌មានសម្ងាត់

អង្គនីតិតុលាការ នឹងខិតខំប្រឹងប្រែងតាមការគួរដើម្បីរក្សាបណ្ដឹងសាទុក្ខ និងព័ត៌មានដែលមាននៅក្នុងបណ្ដឹងនោះជាការសម្ងាត់ ទៅតាមកម្រិតនៃការចាំបាច់ដើម្បីធ្វើការត្រួតពិនិត្យឲ្យបានពេញលេញ និងដោយយុត្តិធម៌។ ប្រសិនបើអង្គនីតិតុលាការ ត្រូវបានតម្រូវដោយច្បាប់ក្នុងការបញ្ចេញព័ត៌មានណាមួយរបស់អ្នក អង្គនីតិតុលាការនោះត្រូវធ្វើការឆ្លើយតបតាមលក្ខខណ្ឌតម្រូវនោះ។

អង្គនីតិតុលាការ នឹងរក្សាទុកបណ្ដឹងសាទុក្ខ និងសំណុំឯកសារ និងឯកសារដទៃផ្សេងទៀតអំពីបណ្ដឹងសាទុក្ខរបស់អ្នកក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចជាស្ថាពរតទៅ។

## សិទ្ធិនិងដំណោះស្រាយបញ្ហាផ្សេងទៀត

នីតិវិធីបណ្ដឹងសាទុក្ខ មិនកំណត់សិទ្ធិនិងដំណោះស្រាយបញ្ហាផ្សេងទៀតដែលអ្នកមានក្រោមច្បាប់នេះនោះទេ។

## សំណួរនិងក្ដីបារម្ភផ្សេងទៀត

អង្គនីតិតុលាការ ប្ដេជ្ញាចិត្តក្នុងការផ្ដល់ជូននូវការទទួលបានសេវាតុលាការពេញលេញនិងយុត្តិធម៌។ ប្រសិនបើអ្នកមានសំណួរឬក្ដីកង្វល់ណាមួយអំពីនីតិវិធីបណ្ដឹងសាទុក្ខនេះ សូមទំនាក់ទំនងអ្នកសម្របសម្រួលសេវាតុលាការ។

Court Access Coordinator
Administrative Office of the Courts
PO Box 4820, Portland ME 04112
ទូរសព្ទ៖ (207) 822-0718
TTY៖ Maine Relay 711
ទូរសារ៖ (207) 776-6096
អ៊ីម៉ែល៖ accessibility@courts.maine.gov

Revised 1/8/18